# ការសម្ភាសន៍របស់អ្នកមីង កែម ម៉ុម

កះ អ្នកសម្ភាសន៍គេ រត្ន ស្រីភាព ខះ អ្នកដែលគេត្រូវសម្ភាសន៍មាន កែវ ម៉ុម

កះ ជាដំបូងខ្ញុំសូមជំរាបសួរអ៊ុំខ្ញុំមានឈ្មោះ រត្ន ស្រីភាពហើយខ្ញុំសូមអនុញ្ញាតសម្ភាសន៍អំពីជីវប្រវត្តិរបស់អ៊ុំដើម្បីទុកអោយកូនជំនាន់ក្រោយអោយបានស្គាល់ថាជីវប្រវត្តិរបស់ដូនតានឹងជីវប្រវត្តិអ៊ុំផងហើយឲ្យកូនចៅរបស់អ៊ុំបានដឹងថាជីវប្រវត្តិរបស់អ៊ុំដែលអ៊ុំធ្លាប់មានកាលលំបាកអ្វីខ្លះនៅក្នុងឆាកជីវិតមួយៗរបស់អ៊ុំ។ហើយខ្ញុំបានធ្វើវាឡើងដោយសាកលវិទ្យាល័យមួយដែលគេហៅថាសាកលវិទ្យាល័យ (ប៊ី វ៉ាយ យូវ) ហើយមានទីតាំងនៅអាមេរិចហើយខ្ញុំសូមអនុញ្ញាតយកសម្លេងរបស់អ៊ុំទៅអោយសាកលវិទ្យាល័យផងដើម្បីរក្សាទុកអោយកូនចៅជំនាន់ក្រោយរបស់អ៊ុំបានស្តាប់ពីជីវកប្រវត្តិរបស់អ៊ុំនឹងដូនតារបស់អ៊ុំ។តើខ្ញុំអាចអនុញ្ញាតយកសម្លេងអ៊ុំយកទៅសាកលវិទ្យាល័យបានទេអ៊ុំ?

ខះ អត់អីទេ!

កះ ហើយខ្ញុំសូមអគុណដែលអ៊ុំបានឲ្យខ្ញុំយកសម្លេងអ៊ុំទៅអោយសាកលវិទ្យាល័យផងដែល។ចា!ការសម្ភាសន៍នេះបានធ្វើឡើងនៅថ្ងៃទី២២ខែ២ឆ្នាំ២០១៨។ចា!ហើយអ៊ុំមានឈ្មោះអ្វីដែលអ៊ុំ?

ខះ ចា!ខ្ញុំមានឈ្មោះថា កែវ ម៉ុម។

កះ ហើយសព្វថ្ងៃនឹងអ៊ុំមានអាយុប៉ុន្មានហើយដែលអ៊ុំ?

ខះ ខ្ញុំមានអាយុ៥២ឆ្នាំហើយ។

កះ អញ្ចឹងតើអ៊ុំមានចាំថ្ងៃខែឆ្នាំកំណើតរបស់អ៊ុំទេថាតើអ៊ុំកើតនៅថ្ងៃណាដែលអ៊ុំ?

ខះ ខ្ញុំភ្លេចបាត់ហើយទល់តែមើលអត្តសញ្ញាណបណ្ណ័។

កះ អញ្ចឹងតើអ៊ុំអាចប្រាប់ខ្ញុំបានទេថាអ៊ុំកើតនូវឆ្នាំខ្មែរដូចជា ជូត ឆ្លូវ ខាល ថោះ?

ខះ ខ្ញុំកើតនៅឆ្នាំមមី។

កះ អញ្ចឹងអ៊ុំកើតនៅឆ្នាំមមីហើយស្រុកកំណើតអ៊ុំនៅឯណាដែលអ៊ុំ?

ខះ ស្រុកកំណើតខ្ញុំនៅព្រៃវែង។

កៈ ហើយអ៊ុំនៅខេត្តព្រៃវែងអញ្ចឹងអ៊ុំប្រាប់ខ្ញុំបានទេថាអ៊ុំរស់នៅភូមិឃុំស្រុកអីដែលអ៊ុំ?

ខៈ ខ្ញុំរស់នៅភូមិទ្រនប់ឃុំប្រធាតុស្រុកពងអណ្ដែតខេត្តព្រៃវែង។

កៈ ហើយបានអ៊ុំផ្លាស់មករស់នៅភ្នំពេញប៉ុន្មានឆ្នាំហើយអ៊ុំ?

ខៈ ខ្ញុំមករស់នៅនិង២ឆ្នាំហើយ។

កៈ អញ្ចឹងអ៊ុំទើបតែមករស់នៅនឹងបានតែរយៈពេល២ឆ្នាំទេអ៊ុំ?

ខៈ ចា!ខ្ញុំទើបតែមករស់នៅនឹងទេ។

កៈ អញ្ចឹងអ៊ុំនៅនឹងគេហៅថាភូមិអីគេដែលអ៊ុំ?

ខៈ គេហៅភូមិព្រែកផ្ទាល។

កៈ ចា!គេហៅភូមិនឹងជាភូមិទី៩នឹងមែនអ៊ុំ?

ខៈ ចា!

កៈ ចា!ហើយអញ្ចឹងអ៊ុំមានបងប្អូនបង្កើតប៉ុន្មាននាក់ដែលអ៊ុំ?

ខៈ ខ្ញុំមានបងប្អូនបងង្កើត៥នាក់។

កៈ តើអ៊ុំជាកូនទីប៉ុន្មានដែលអ៊ុំ?

ខៈ ចា!ខ្ញុំជាកូនទី១។

កៈ
អញ្ចឹងអ៊ុំជាកូនទី១ហើយអ៊ុំជាកូនទីមួយអ៊ុំនឿយហត់ខ្លាំងណាស់ហើយលើបន្ទុកគ្រួសារ។ ហើយអ៊ុំមានបងប្អូនប្រុសស្រីប៉ុន្មាននាក់ដែលអ៊ុំ?

ខៈ ចា!ខ្ញុំមានបងប្អូនប្រុសខ្ញុំមាន១នាក់ស្រី៤នាក់។

កៈ ចា!ចឹងអ៊ុំមានបងប្អូនប្រុស១នាក់ស្រី៤នាក់
ចា!អញ្ចឹងអ៊ុំជាកូនច្បង។អញ្ចឹងអ៊ុំបានចាំទេថាបងប្អូនអ៊ុំពួកគាត់មានឈ្មោះអ្វីខ្លះ?

ខៈ ខ្ញុំចាំ!

កៈ ប្អូនទី២អ៊ុំមានឈ្មោះអ្វីដែលអ៊ុំ?

ខៈ ប្អូនទី២បន្ទាប់ពីខ្ញុំនឹងមានឈ្មោះថា កែវ តូច។

កៈ ហើយប្អូនទី៣មានឈ្មោះអ្វីដែលអ៊ុំ?

ខ៖ ប្អូនទី៣ខ្ញុំមានឈ្មោះថា កែវ សុភាព។

ក៖ ចា!ហើយឈ្មោះប្អូនទី៣ឈ្មោះថា កែវសុភាពអញ្ចឹងប្អូនទី៤មានឈ្មោះអ្វីដែលអ៊ុំ?

ខ៖ ប្អូនទី៤មានឈ្មោះថា កែវ សុភា។

ក៖ ចា!ហើយប្អូនទី៥របស់អ៊ុំវិញគាត់មានឈ្មោះអ្វីដែលអ៊ុំ?

ខ៖ មានឈ្មោះថា កែវ ពិសិដ្ធ។

ក៖ ចា!ប្អូនទី៤មានឈ្មោះថា កែវ ពិសិដ្ធ?

ខ៖ ចា!នឹងហើយប្អូនពៅគេ។

ក៖ ចា!ហើយអ្នកមីងមានកត្តាកិច្ចចិញ្ចឹមពួកគាត់តាំងពីអាយុប៉ុន្នាហើយមកអ្នកមីង?

ខ៖ ចា!ធ្វើការរកស៊ីចិញ្ចឹមពួកគាត់ជាមួយឪពុកម្តាយ។

ក៖ ចា!ចិញ្ចឹមពួកគាត់រហូតមកទៅ?

ខ៖ ចា!ចិញ្ចឹមពួកគាត់ជាមួយឪពុកម្តាយរហូចមកនិង។ហើយរកស៊ីជុំគ្នាមក។

ក៖
ចា!ហើយអញ្ចឹងអ្នកមីងមានបន្ទាប់ជាច្រើនសម្រាប់អ្នកមីង?ចា!អញ្ចឹងហើយឥឡូវពួកគាត់មានការងារធ្វើហើយឥឡូវនឹងអ្នកមីង?

ខ៖
ពីមុនគេធ្វើស្រែចំការអញ្ចឹងទៅហើយឥឡូវគេទៅរកស៊ីនៅខាងក្រៅទៅមានតែខ្ញុំទេធ្វើអីអត់កើត។

ក៖ ចា!ហើយអ្នកមីកមានបានទៅស៊ីឈ្នួលនៅឯណាទៀតទេអ្នកមីង?

ខ៖ អត់ទេអត់ដែលផងហើយឥឡូវនឹងចាស់ហើយ។

ក៖ ចា!ហើយអ្នកមីងទើបតែធ្លាក់ខ្លួនក្រទេអ្នកមីង?

ខ៖ ចា!

ក៖ ចា!អញ្ចឹងពីមុនអ្នកមីងជាកូនអ្នកមានម្នាក់ដែលអ្នកមីង?

ខ៖
វាជាមិនមានអីប៉ុន្មានទេគ្រាន់តែមធ្យមភាគតែដល់ពេលធ្លាក់ខ្លួនទៅអត់ដឹងធ្វើអីកើតហើយខ្ញុំមានប្តីទៀតខ្ញុំក៏បានមកនៅនិងទៅ។

កៈ ហើយបងប្អូនរបស់អ្នកមីងរស់នៅទាំងអស់គ្នាមែងអ្នកមីង?

ខៈ នៅទាំងអស់គ្នា។

កៈ ហើយអញ្ចឹងពួកគាត់នៅណាខ្លះអ្នកមីង?

ខៈ គាត់នៅស្រែបីនាក់ហើយអាប្អូនមួយរកស៊ីនៅកាណាឌីយ៉ា។

កៈ នៅភ្នំពេញមួយនាក់។

ខៈ ចាំ! នៅភ្នំពេញមួយនាក់ហើយនិងខ្ញុំ។

កៈ ចាំ! តែនៅផ្សេងគ្នាគាត់និងប្អូនពៅមែនអ្នកមីង។

ខៈ និងហើយប្អូនពៅគេគាត់ប្រុស។

កៈ ប្អូនប្រុសរបស់អ្នកមីងធ្វើការចែកសន្លឹកបៀរគេមែនអ្នកមីង។

ខៈ អត់ទេវាលក់ក្រូចនៅមុខវត្តចម្ការន្ត។

កៈ ចាំ! តែនៅក្បែរកាណាឌីយ៉ានិងអ្នកមីង។

ខៈ ចាំ!

កៈ អញ្ចឹងអ្នកមីងមានចាំឈ្មោះឪពុកម្តាយរបស់អ្នកមីងទេ?

ខៈ ចាំ! ចាំតើ!

កៈ អញ្ចឹងលោកឪពុកមានឈ្មោះអ្វីដែរអ្នកមីង?

ខៈ ឪពុករបស់ខ្ញុំមានឈ្មោះថា កែវ សាន។

កៈ ចំនែកអ្នកម្តាយមានឈ្មោះអ្វីដែរអ្នកមីង?

ខៈ អ្នកម្តាយមានឈ្មោះ នួត ហួត។

កៈ តើអ្នកមីងមានចាំឆ្នាំកំណើតរបស់គាត់ថាគាត់កើតនៅឆ្នាំដូចជា ជូត ឆ្លូវ ខាល ថោះ អីទេអ្នកមីង?

ខៈ ចាំ! លោកឪពុកគាត់ឆ្នាំ រកា ហើយអ្នកម្តាយខ្ញុំឆ្នាំ ជូត។

កៈ ចាំ! ហើយអ្នកមីងមានចាំថាសព្វថ្ងៃគាត់នៅមានប្រជ្ញានទេអ្នកមីង?

ខៈ លោកឪពុកនិងអ្នកម្តាយនៅទាំងពីរ។

កៈ ចាំ! ហើយអ្នកម្តាយរបស់អ្នកមីងមានអាយុប៉ុន្មានហើយ?

ខៈ ម្តាយរបស់ខ្ញុំមានអាយុចិតសិបបីឆ្នាំហើយ។

កៈ តែគាត់នៅស្រុកកំណើតនិងមែនអ្នកមីង។

ខៈ ស្រុកកំណើតនៅ ពងអណ្តែតនិង។

កៈ អញ្ចឹងរស់នៅខេត្តព្រៃវែងនិង។

ខៈ ចាំ! គាត់រស់នៅនិង។

កៈ អញ្ចឹងគាត់រស់នៅជាតែពីរតាហើយនិងយាយនិងតាអ្នកមីង?

ខៈ គាត់រស់នៅជាមួយប្អូននៅឯស្រុកនិងនៅជាមួយមីប្អូនបន្ទាប់ពីពៅនិងឈ្មោះ កែវ សុភានិង។

កៈ ចាំ!
អញ្ចឹងអ្នកមីងមាននៅចាំថាពេលអ្នកមីងនៅពីក្មេងតើលោកឪពុករបស់អ្នកមីងប្រកបមុខរបរអ្វីចិញ្ចឹមអ្នកមីង។

ខៈ គាត់ធ្វើតែស្រែទេ។

កៈ ចាំ! គាត់អត់ធ្វើអ្វីផ្សេងទៀតទេអ្នកមីង?គាត់ធ្វើតែស្រែទេ។

ខៈ គាត់អត់ធ្វើអ្វីទេគាត់ធ្វើតែស្រែទេ។

កៈ ហើយលោកឪពុករបស់អ្នកមីងមានបានធ្វើទាហានទេអ្នកមីង?

ខៈ គាត់អត់ដែរធ្វើទាហានទេ។

កៈ ហើយធ្វើតែស្រែសុទ្ធស្រាកតែម្តង។

ខៈ ចាំ!

កៈ ហើយរកស៊ីចិញ្ចឹមអ្នកមីងហើយនិងប្អូនៗរបស់អ្នកមីងទៅ។

ខៈ ចាំ!

កៈ ចាំ! អញ្ចឹងអ្នកមីងគិតថាពួកគាត់ជាមនុស្សបែបណាដែរអ្នកមីង។

ខៈ ចាំ!

កៈ ហើយលោកឪពុករបស់អ្នកមីងជាមនុស្សបែបណាដែរ?

ខ៖ គាត់ជាមនុស្សល្អគាត់គ្រាន់ជាកសិករម្នាក់។

ក៖ គាត់ជាមនុស្សល្អហើយស្លូតបូតមែនអ្នកមីង?

ខ៖ ចាំ! គាត់ជាមនុស្សល្អហើយស្លូតបូតហើយគាត់ជាអ្នកកាន់ធម្មអាហើយជាអាចារ្យវត្តផងដែរ។

ក៖ លោកតាគាត់ធ្វើអាចារ្យហើយអ្នកម្ដាយនៅផ្ទះ។

ខ៖ គាត់មានពេលទំនេរគាត់ទៅវត្តទៅ។

ក៖ ចាំ! ហើយគាត់ជួយក្រុមគ្រួសារបន្ថែមទៀតទៅដើម្បីជួយចិញ្ចឹមលោកយាយដែរ។

ខ៖ ចាំ!

ក៖ ហើយអ្នកមីងមាននូវចាំថាពេលនៅជាមួយឪពុកម្ដាយកាលនៅក្មេងតើអ្នកមីងចាំជីវិតដល់ជូរជត់ជាមួយគាត់កាលនៅពីក្មេងហើយបើនៅសម័យប៉ុលពតវិញតើអ្នកមីងមាននូវចាំទេពេលនៅជាមួយគាត់។

ខ៖ ខ្ញុំចាំបានតិចៗអត់សូវចាំបានច្រើនទេវាជិតដប់ឆ្នាំហើយ។

ក៖ អញ្ចឹងអ្នកមីងមានចាំថានៅជំនាន់អ្នកមីងកើបអាចម៍គោទេអ្នកមីង?

ខ៖ និងហើយកាលពីជំនាន់និងខ្ញុំនៅកើបអាចម៍គោឲ្យគេចិតត្រពាំងពេលភ្លឺឡើងគេឲ្យដេកបាតត្រពាំងហើយដាក់ភ្លឺត្រពាំងទៅ។

ក៖ ចាំ!ៗ

ខ៖ មួយម្នាក់ហាសិបខ្ទងមួយរយខ្ទងអីអញ្ចឹងទៅ។

ក៖ ចាំ!

ខ៖ វាដាក់ឲ្យកំណត់អញ្ចឹងទៅណាស់ហើយថ្ងៃឡើងបានធ្វើការទៀតទៅហើយខែវស្សាយើងកើបអាចម៍គោអញ្ចឹងទៅ។

ក៖ អញ្ចឹងកើបអាចម៍គោទៅហើយវាឲ្យកាប់គង្គាងខែទៅ។

ខ៖ វាឲ្យយើងកាប់គង្គាងខែទៅ។

ក៖ ហើយអ្នកមីងមាននៅចាំឈ្មោះលោកតាលោកយាយអ្នកមីងទេអ្នកមីង?

ខ៖ ឈ្មោះលោកយាយលោកតាខាងណាដែរ?

ក៖
ដូចជាឈ្មោះលោកតាហើយលោកយាយខាងលោកឪពុករបស់អ្នកមីងហើយនិងខាងម្ដាយរបស់អ្នកមីង?

ខ៖ លោកតាខាងឪពុកខ្ញុំគាត់មានឈ្មោះតា ហូត ហើយយាយទាប។

ក៖
ហើយតើអ្នកមីងមាននៅចាំពេលគាត់នៅរស់នៅតើបានធ្វើអ្វីខ្លះដល់ក្រុមគ្រួសារអ្នកមីងហើយនិងបានជួយដល់អ្នកមីងអ្វីខ្លះអ្នកមីង?

ខ៖ គាត់ធ្វើតែស្រែនិងគាត់គ្មានមុខរបរណាផ្សេងទេក្រៅពីធ្វើស្រែហើយគាត់នៅផ្ទះ។

ក៖ ចាំ!

ខ៖ ចាំ! អ្នកស្រែធ្វើតែស្រែក្រៅស្រែគ្មាន់អ្វីធ្វើទេនិងជាធម្មតា។

ក៖ ចា!

ខ៖ ដល់រដូវធ្វើស្រែយើងធ្វើស្រែទៅ។

ក៖
ចា!អញ្ចឹងគាត់ធ្វើស្រែចំការអញ្ចឹងទៅអ្នកមីង?សូមទោសអ្នកមីងតើអ្នកមីងមាននៅចាំទេពីអនុស្សាវរីយដែលអ្នកមីងមានជាមួយឪពុកម្ដាយដែលពួកគាត់បានយកអ្នកមីងទៅតាមពួកគាត់ហើយអ្នកមីងមាននៅចាំបានខ្លះទេអ្នកមីងដែលអ្នកមីងបានឃើញហើយបានចាំអំពីទិន្នភាពអ្វីខ្លះអ្នកមីង?

ខ៖
ដូចជាខ្ញុំបានរស់នៅជាមួយពួកគាត់ទាំងយប់ទាំងថ្ងៃគាត់បានជួយមើលកូនចៅដែលគាត់ថាគាត់នឹងជួយបានតែរឿងតូចតាចតែប៉ុណ្ណោះ។

ក៖ ចា!

ខ៖
ហើយបានដែលយាយគាត់មានរាងមាំហើយខ្ញុំបាននៅជាមួយគាត់ទាំងយប់ទាំងថ្ងៃដែលនឹងហើយកូនចៅដែលខ្ញុំចិញ្ចឹមបានធំហើយបានគាត់ជួយមើលនឹង។

កៈ ចា!ហើយគាត់ជួយមើលកូនចៅអីអញ្ចឹងទៅ?

ខៈ ចា!គាត់ជួយមើលពេលយើងរវល់ធ្វើការអញ្ចឹងទៅទើបគាត់ជាអ្នកមើលកូនចៅទៅ។

កៈ ចា!ហើយគាត់បានជួយមើលការខុសត្រូវអោយយើងទៅពេលយើងរវល់ធ្វើការងារ?

ខៈ
ចា!គាត់បានជួយបានតែប៉ុណ្ណឹងទេ។ហើយដល់ពេលដែលយើងដើរទៅណាចឹងគាត់ជួយយកទៅដាក់អង្រឹងគាត់ជួយយ៉ូឲ្យយើងទៅ។

កៈ
ចា!សម្រាប់ដែលគាត់បានជួយយើងបានតែប៉ុណ្ណឹងទេហើយឲ្យអស់ពីសម្ពាតភាពគាត់ទៅ?

ខៈ ចា!

កៈ ចា!ហើយលោកតាលោកយាយរបស់អ្នកមីងគាត់រស់នៅខេត្តព្រៃវែងនឹងមែនអ្នកមីង?

ខៈ គាត់បានផ្លាស់ប្តូលមករស់នៅនិងរហូតមកតាំងពីគាត់កើតមកម្លេះ។

កៈ ដូចជាគាត់បានរស់នៅតាំងពីតូចមកអ្នកមីង?

ខៈ ចា!គាត់បានរស់នៅនឹងតាំងពីកំណើតគាត់មកម្លេះហើយ។

កៈ
អញ្ចឹងអ្នកមីងមាននៅចាំថាអ្នកមីងមានបងប្អូនដែលគាត់ទៅរស់នៅក្រៅប្រទេសដូចជាប្រទេសថៃឬវៀតណាមទេអ្នកមីង?

ខៈ  ខ្ញុំអត់មានបងប្អូននៅក្រៅប្រទេសទេ ។ បងប្អូនខ្ញុំនៅស្រុកកំណើតទាំងអស់គ្នា ។

កៈ ហើយអ្នកមីងបានរៀបអាពាហ៍ពិពាហ៍ជាមួយប្តីរបស់អ្នកមីង
ហើយប្តីអ្នកមីងគាត់មានឈ្មោះអ្វីដែលអ្នកមីង?

ខៈ ប្តីរបស់ខ្ញុំគាត់មានឈ្មោះថាពៅ ជា។

កៈ ហើយអ្នកមីងបានរៀបការនៅអាយុប៉ុន្មានដែលអ្នកមីង។

ខៈ ខ្ញុំបានរៀបការនៅអាយុ២៧ឆ្នាំ។

កៈ ចាំ
ហើយអាពាហ៍ពិពាហ៍របស់អ្នកមីងរៀបចំឡើងដោយឪពុកហើយនិងអ្នកម្តាយរបស់អ្នកមីងរឺក៏អ្នកមីងរៀបចំឡើងដោយខ្លួន ឯងអ្នកមីង។

ខ៖
អាពាហ៏ពិពាហ៏និងគឺឪពុកហើយអ្នកម្តាយខ្ញុំគាត់ជាអ្នករៀបចំអោយខ្ញុំមានប្តីរបស់ខ្ញុំនិង។

ក៖ ចា៎! ហើយគាត់បានបែកពីអ្នកមីងដោយសាររឿងអ្វីដែលអ្នកមីង។

ខ៖ ចា៎! បានទៅមានប្រពន្ធមួយទៀយហើយគាត់បានលែងខ្ញុំទៅ។

ក៖ ហើយគាត់បានធ្វើបាកផ្លូវចិត្តរបស់អ្នកមីងទេកន្លងមកអ្នកមីង។

ខ៖ ចា៎! គាត់បានធ្វើបាកច្រើនណាស់។

ក៖
កាត់ជាមនុស្សដែលមិនទទួលខុសត្រូវលើកកូនចៅទេហើយគាត់ជាមនុស្សដែលមិនទទួល
និងមិនជួយកូនចៅនិងការងាររបស់ប្រពន្ធ។
អញ្ចឹងអ្នកមីងអាចប្រាប់ខ្ញុំបានទេថាពេលដែលគាត់បានរស់នៅជាមួយគាត់អ្នកមីងមានការ
លំបាកអ្វីខ្លះអ្នកមីង។

ខ៖ ខ្ញុំពិបាករៀបរាប់មិនអស់ទេហើយខ្ញុំពិបាកនិយាយណាស់បើនិយាយទៅវាមិនអស់ទេ។

ក៖ អូចា៎ចឹង!
តើអ្នកមីងមានចាំថាស្វាយមីអ្នកមីងមានជូនជំនួនថ្លៃទឹកដោះប៉ុន្មានអោយអ្នកមីងហើយការ
និងអ្នកមីងមានចាំទេអ្នកមីងអាដែលចូលមកស្តីដណ្តឹងអ្នកមីងអីអញ្ចឹងណាអ្នកមីង។

ខ៖ គាត់បានជូនខ្ញុំបាន២៥០០០រៀលមីងអូន។

ក៖ អូ! កាលនិងអ្នកមីងបានច្រើននៃ់អ្នកមីង។ចា៎
ហើយអ្នកមីងបានស្គាល់គាត់ពីកន្លែងណាពីមុងមកណាអ្នកមីង។

ខ៖
ខ្ញុំមិនបានស្គាលគាត់នៅកន្លែងណាទេដោយសារខ្ញុំនិងគាត់ជាបងប្អូនជីដូនមួយនិងគ្នាដោ
យសារឪពុកខ្ញុំនិងឪពុកគាត់និងត្រូវនិងបងប្អូននិងគ្នា។

ក៖ ចា៎!

ខ៖ ហើយគាត់បានមើលឃើញខ្ញុំទៅគាត់បានអោយឪពុកគាត់និងមកស្តីដណ្តើងខ្ញុំទៅ។

ក៖ ចា៎!
ហើយអ្នកមីងជាបងប្អូននិងគាត់ដែលសោះនិងហេតុអីគាត់ធ្វើបាកអ្នកមីងដល់ម្លឹង។ហើយ
អ្នកមីងបានរៀបការជាមួយនិងគាត់និងបានកូនប៉ុន្មានដែលអ្នកមីង។

ខ៖ ខ្ញុំបានកូនពីរនាក់។

ក៖ ចាំ! ហើយប្រុសមួយស្រីមួយមែនអ្នកមីង។

ខ៖ ចាំ!
អត់ទេស្រីពីរហើយកូនខ្ញុំបានស្លាប់បាត់មួយហើយគាត់បានស្លាប់ដោយសារហាមរីក។

ក៖ ចាំ! គាត់ស្លាប់ដោយសារអីអ្នកមីងគាត់ស្លាប់ដោយសារមហារីកមែនអ្នកមីង។

ខ៖ ចាំ! គាត់បានកើតបានបី បួនខែហើយគាត់បានស្លាប់។

ក៖ អរ! អញ្ចឹងគាត់បានចែកឋានយូរដែលអ្នកមីង។

ខ៖ ចាំ!

ក៖ ហើយនៅជាមួយកូនស្រីតែមួយនាក់ទៅអ្នកមីង។

ខ៖ ចាំ!

ក៖ ហើយអ្នកមីងមានបានចូលសាលារៀនទេកាលនៅពីក្មេងមកអ្នកមីង។

ខ៖ ខ្ញុំបានចូលរៀនដែរ។

ក៖
អញ្ចឹងអ្នកមីងបានចូលរៀនដែលអ្នកមីងហើយអ្នកមីងអាចសរសេរអក្សរខ្មែរខ្លះៗទេដូចខ្ញុំលឺថាអ្នកមីងអាចសរសេរបានអ្នកមីង។

ខ៖ ចាំ! ខ្ញុំអាចសរសេរបានតាហើយខ្ញុំក៏អាចអានបានដែរ។

ក៖ ចាំ!

ខ៖ ខ្ញុំបានរៀនបានថ្នាក់ទីប្រាំ។

ក៖ ចាំ!

ខ៖ កាលពីជំនាន់និងខំអីខ្ញុំរៀនចប់ហើយតែខ្ញុំវាក្រអត់បានរៀនដូចគេទេ។

ក៖ ចាំ!

ខ៖ ហើយខ្ញុំបានឈប់រៀនទៅ។

ក៖
ព្រោះឪពុកម្ដាយក្រពេកអ្នកមីង។ហើយអញ្ចឹងអ្នកមីងមានចេះភាសាអ្វីផ្សេងទៀតទេព្រោះកាលពីសម័យនិងបារាំងចូលពេញបន្ទុកហើយ។

ខ៖ អត់ចេះទេបានត្រឹមតែអក្សរខ្មែរនិងបានហើយ។

ក៖ ចាំ!

ខ៖ និងហើយរៀនតែអក្សរខ្មែរឲ្យចេះសរសេរហើយបានអាននិងបានហើយ។

ក៖ អញ្ចឹងអក្សរបារាំងនិងអ្នកមីងបានរៀនទេ។

ខ៖ ចាំ! ខ្ញុំអត់ចេះទេ។

ក៖
អញ្ចឹងអ្នកមីងអាចប្រាប់ខ្ញុំបានទេថាអ្នកមីងបានរៀនត្រឹមថ្នាក់ទីប្រាំនិងតើសាលាអ្នកមីងរៀនមានឈ្មោះអ្វីដែរ?

ខ៖ មានឈ្មោះថាសាលាបឋមសិក្សា ថ្នាត ឆ្កាង។

ក៖ សាលាបឋមសិក្សា ថ្នាត ឆ្កាង។

ខ៖ ចាំ!

ក៖ សាលា ថ្នាត កាននៅខេត្ត ព្រៃវែងនិងមែនអ្នកមីង។

ខ៖ ចាំ!

ក៖ ហើយសព្វថ្ងៃនិងសាលារៀននិងគេប្ដូរឈ្មោះនូវអ្នកមីង?

ខ៖ សាលានិងនៅមានឈ្មោះដំដែលឥឡូវឡើងទៅអនុវិទ្យាល័យឬវិទ្យាល័យហើយ។

ក៖ ប៉ុន្តែមានឈ្មោះដំដែរ។

ខ៖ ចាំ! ពេលទៅដល់គេដាក់រូបថ្នាតហើយគេសរសេរអក្សរដូចរូបនិង។

ក៖ ចាំ! ហេតុអីបានជាគេដាក់ឈ្មោះនិងទៅអ្នកមីង។

ខ៖ គេមានប្រវត្តិគេ។

ក៖ តើមានប្រវត្តិអ្វីទៅអ្នកមីងអាចប្រាប់ខ្ញុំបានទេអ្នកមីង?

ខ៖
ខ្ញុំបានលឺពីចាស់ៗមកពីភូមិនិងក្រពេកហើយគាត់ថាពីដើមមកមានថ្មាតចុះមកផឹកទឹកត្រពាំងពេលថ្ងៃក្ដៅហើយបានចាស់បានហៅថ្មាត ឆ្កាងនិងទៅ។

ក៖ អញ្ចឹងបានគេហៅថាថ្មាត ឆ្កាង។

ខ៖
ព្រោះតែថ្មាតនិងចុះមកផឹកទឹកត្រពាំងហើយវាកាងទឹកនិងហើយបានគេហៅថ្មាតកានហើយត្រពាំងនិងរាំងទៅហើយគេហៅតគ្នារហូតទៅ។

ក៖ អញ្ចឹងដោយសារតែថ្មាតនិងកាងត្រពាំងនិងទៅ។

ខ៖ ចាំ! អញ្ចឹងគេហៅថ្មាត ឆ្កាងទៅខ្ញុំលឺចាស់ៗគាត់និយាយទៅខ្ញុំអត់ដឹងច្បាស់ដែលនិង។

ក៖ ដោយសារតែថ្មាតនិងកាងមិនឲ្យគេចូលផឹកទឹកឬមិចអ្នកមីង?

ខ៖
អត់ទេគឺថ្មាតនិងវាឆ្កាងនៅនិងហើយដូចវាត្រដាងស្លាបវាកុំឲ្យក្ដៅហើយនៅលើឃ្លោងទ្វារគេដាក់រូបថ្មាតនិងទៅ។

ក៖ ចាំ! អញ្ចឹងទៅពេលចុះទៅឃើញរូបថ្មាត ឆ្កាងនៅលើឃ្លោងទ្វារនិងទៅ។

ខ៖ ចុះទៅប្រហែល បីទៅបួនគីឡូទៀតបានឃើញ។

ក៖ អញ្ចឹងមានសាលានិងរហូតទៅ។

ខ៖ ចាំ! បានជាគេហៅថា ថ្មាត ឆ្កាង អញ្ចឹងរហូតទៅ។

ក៖ អញ្ចឹងទៅបានមានសាលារៀនថ្មាត ឆ្កាងអញ្ចឹងរហូតទៅ។

ខ៖ គេមានប្រវត្តិគេពីដើមមកខ្ញុំអត់សូវដឹងច្បាស់ដែរ។

ក៖ ចាំ!
ពេលដែលអ្នកមីងបានរៀនបានត្រឹមថ្នាក់ទីប្រាំហើយអ្នកមីងមានមិត្តភក្ដិជិតស្និតទៅអ្នកមីង។

ខ៖ ដូចជាអត់មានទេតាំងពីក្មេងមក។

ក៖ អ្នកមីងអត់មានមិត្តភក្ដិជិតស្និតទេ។

ខ៖ ខ្ញុំមានតែមីងមារនៅជិតនិង។

កៈ ចាំ!ៗ

ខៈ ខ្ញុំគ្មានមិត្តភក្តិដូចគេទេ។

កៈ អញ្ជឹងអ្នកមីងមានស៊ីឈ្នួលគេស្ទូងស្រូវទេ។

ខៈ ខ្ញុំធ្លាប់តើស៊ីឈ្នួលគេពេលគេដកហើយទៅខ្ញុំសុំគេស្ទូងគេទៅ។

កៈ ហើយក្រៅពីស៊ីឈ្នួលគេស្ទូងស្រូវតើអ្នកមីងមានធ្វើការអ្វីបន្ថែមទៀតទេអ្នកមីង?

ខៈ អត់ធ្វើអីទៀត។

កៈ អញ្ជឹងអ្នកមីងបានស្ទូងស្រូវឲ្យគេបានតែរដូវវស្សាទេហើយរដូវប្រាំងតើអ្នកនៅខេត្តព្រៃវែងគាត់ធ្វើអ្វីទៅនៅរដូវនិង។

ខៈ គេរកស៊ីរៀងៗខ្លួនទៅនាក់ខ្លះគេរកស៊ីទៅឯអ្នកខ្លះគេធ្វើស្រែទៅ។

កៈ ចាំ! អ្នកនៅនិងគេរកស៊ីទៅ។

ខៈ ពីមុនខ្ញុំរកស៊ីដែលដល់ពេលពិបាកពេកទៅខ្ញុំក៏ដើរទៅលក់បន្លែដូចជាស្លឹកបាសបន្លែតិចតួច។

កៈ ចាំ!ៗ

ខៈ យើងអត់មានដើមទុនមានតែលក់បន្លែសិនដើម្បីយកដើមទុន។

កៈ ចាំ! ហើយក្នុងការលក់បន្លែនិងអ្នកមីងបានកំរៃគ្រាន់បើតាអ្នកមីងអាចបានបីបួនម៉ឺនដែលអ្នកមីង។

ខៈ វាមិនសល់ទៅរាល់ថ្ងៃនិងបានតែប្រាក់ខែកូននិង។

កៈ ចាំ!
អញ្ជឹងបានប្រាក់ខែកូនបានគ្រប់គ្រាន់សម្រាប់ប្រើប្រាស់នៅក្នុងគ្រួសារហើយអ្នកមីងត្រូវតស៊ូព្យាយាមជីវិតរបស់ប្រជាជនខ្មែរយើងអញ្ជឹងមានជួបបញ្ហាខ្លះៗនូវក្នុងជីវិត។

ខៈ ចាំ! ត្រូវតែតស៊ូព្យាយាម។

កៈ ចាំ!
បើយើងគ្មានការព្យាយាមហើយឃ្នាសឃ្នែងទេពិតជាពិបាក។ហើយអ្នកមីងអាចប្រាប់ខ្ញុំបានទេថាជីវិតរបស់តើមានការជួបការលំបាកអ្វីខ្លះនៅក្នុងជីវិតហើយបើអាចផ្លាស់ប្តូរអ្នកមីងចង់ផ្លាស់ប្តូរទេអ្នកមីង?

ខ៖ ជីវិតខ្ញុំមានការលំបាកណាស់បើនិយាយទៅ
មានការជួបការលំបាកជាច្រើនក្នុងការរកស៊ីមានការជួបពិបាកណាស់។

ក៖ ចាំ!
ការរកស៊ីតែងតែមានការលំបាកហើយមានការចំនាញខ្លះទៅមានការខាតបង់វាអត់ទៀងទេអ្នកមីង។

ខ៖ និយាយឲ្យចំទៅក្នុងម៉ាឆាកជីវិតពិបាកណាស់។

ក៖ ចាំ! បើឲ្យស្រួលក៏លំបាកដែលអ្នកមីង។

ខ៖ ចាំ! ឆាកជីវិតរបស់មនុស្សវាពិបាកណាស់។

ក៖ ចាំ! ហើយអញ្ចឹងអ្នកមីងចូលចិត្តម្ហូបអីដែរអ្នកមីងទាំងពីតូចមកដល់ឥឡូវនិង?

ខ៖ ធម្មតាទេមានអីហូបនិងខ្ញុំមិនដែលរើសទេ។

ក៖ ចាំ!

ខ៖ ពេលខ្លះយើងបានទិញត្រីមកធ្វើម្ហូបញ៉ាំធម្មតាទៅ។

ក៖ ចាំ! មិនរើសម្ហូបទេបានធ្វើអីទេក៏បានឲ្យតែបានញ៉ាំចឹងអ្នកមីង។

ខ៖ ចាំ!

ក៖ អញ្ចឹងអ្នកមីងអាចប្រាប់ខ្ញុំបានទេថាអ្នកមីងចូលចិត្តលេងល្បែងប្រជាប្រិយដូចជា ចោលឈូង បោះអង្គញ ទាញព្រោត
ពេលដល់រដូវបុណ្យទានម្តងតើអ្នកមីងចូលចិត្តលេងល្បែងអីដែលអ្នកមីង?

ខ៖ ខ្ញុំចូលចិត្តលេងចោលឈូងពេលមានបុណ្យ។

ក៖ ពេលដែលអ្នកមីងបានពេលនិងមានអារម្មណ៍ថាសប្បាយទេអ្នកមីង?

ខ៖ សប្បាយណាស់ពេលនិង។

ក៖
តែដល់ពេលធំឡើងលែងបានលេងហើយត្រូវមានភារកិច្ចចិញ្ចឹមកូន។ហើយអ្នកមីងចេះច្រៀងទេ។

ខ៖ ខ្ញុំអត់ចេះច្រៀងទេ។

ក៖ អញ្ចឹងអ្នកមីងចេះរាំទេអ្នកមីង។

ខ៖ អត់សូវចេះរាំទេ។

ក៖
អញ្ចឹងអ្នកមីងបានបិទសិទ្ធខ្លួនឯងហើយអញ្ចឹងអ្នកមីងមានបងប្អូនដែលគាត់ចេះលេងភ្លេងដូចជា ខ្លុយ រមៀត ទ្រ ឬឧបករណ៍ផ្សេងទេអ្នកមីង។

ខ៖ អត់មានទេ។

ក៖
អត់មានទេអ្នកមីង។ហើយខ្ញុំសុំសួរអ្នកមីងបន្តិចផ្ទះរបស់អ្នកមីងដែលរស់នៅជាមួយលោកឪពុកអ្នកម្តាយរបស់អ្នកមីងនៅឯស្រុកមានលក្ខណ៍ធំឬតូច។

ខ៖ ផ្ទះរបស់ខ្ញុំមានរាងតូចដែលទេហើយដំបូលប្រក់សាំងអាសីប៉។

ក៖ ដំបូលប្រក់សាំងអាសីប៉ហើយជញ្ជាំងអ្វីដែលអ្នកមីង។

ខ៖ ជញ្ជាំងប្រក់ស្លឹក។

ក៖ សម័យនិងគេនៅមានស្លឹកអញ្ចឹងទៀតអ្នកមីង។

ខ៖ គេនៅមាន។

ក៖ ហើយរណាបធ្វើអំពីដើមឬស្សី។

ខ៖ ចាំ! និងហើយអាររណាបឬស្សីយើងនិង។

ក៖ ចាំ!
មានកម្ពស់មួយម៉ែត្រឡើងទៅអ្នកមីងហើយពេលនិងលោកឪពុកអ្នកមីងធ្វើខ្លួនឯងឬក៏ជួលគេអ្នកមីង។

ខ៖ គាត់បានជួលគេធ្វើខ្លះហើយគាត់ជួយគេខ្លះ។

ក៖ អញ្ចឹងគាត់ជួលគេហើយគាត់ធ្វើខ្លួនឯងខ្លះទៅ។

ខ៖ ចាំ! គាត់ជួយគេធ្វើនិង។

ក៖ ចាំ! ហើយសម្រាប់សម្ភារវិញមានអ្វីខ្លះអ្នកមីង?

ខ៖ មានឈើហើយមានដែកគោលអីផ្សេងទៀតទៅ។

ក៖ មានដែកគោលហើយមានដែកគោលមូកហើយមានដែកសសេស ពូថៅ កាំបិត
ហើយអ្នកមីងមានចេះធ្វើស្ករត្នោតហើយសប្បិកម្មធ្វើកន្ទេលដែលបន្តពីគាត់ទេអ្នកមីង។

ខ៖ អត់មានចេះអីទេ។

ក៖ ធ្វើស្ករត្នោតក៏អត់ចេះដែលតែអ្នកខេត្ត ព្រៃវែងគេនិយមធ្វើកន្ទេលគក់ច្រើនណាស់។

ខ៖ ខ្ញុំអត់ចេះទេ។ខ្ញុំធ្វើតែស្រែតែគេធ្វើកន្ទេលនិង។

ក៖ យើងខុសខេត្តគ្នាអ្នកមីង។

ខ៖ នៅខេត្តជាមួយគ្នាទេតែខ្ញុំអ្នកជនបទធ្វើតែស្រែចំការទេ។

ក៖ អញ្ចឹងឆ្ងាយពេកអត់ចេះទេអ្នកមីង។

ខ៖ ចាំ!

ក៖
ហើយឆាកជីវិតរបស់អ្នកមីងមានការលំបាកអ្វីខ្លះពេលដែលអ្នកមីងដើរទូលនំលក់អញ្ចឹង។

ខ៖ រាល់ថ្ងៃនិងលំបាកណាស់ខ្ញុំដើរតាមលក់តាមផ្ទះគេពេលខ្លះយកទៅលក់នៅឯផ្សារ។

ក៖ ចាំ! ដើរតាមលក់តាមផ្ទះហើយការលំបាកជាងគេរបស់អ្នកមីងហើយដើរទៅលក់ផ្សារ។

ខ៖ ដើរទូលលក់តាមផ្ទះគេហើយទៅផ្សារនិង។

ក៖ ហើយមានពេលណាអ្នកមីងសប្បាយចិត្តខ្លះទេ។

ខ៖ គ្មានថ្ងៃសប្បាយចិត្តទេជីវិតខ្ញុំនោះ។

ក៖
ហើយអ្នកមីងមានក្តីស្រមៃខ្លះទេកាលពីតូចដូចមានបំណងចង់បានធ្វើអ្វីមួយហើយមានបំណងចង់បានទិញដីផ្ទះមួយនៅភ្នំពេញ។

ខ៖
បើខ្ញុំមានលុយខ្ញុំចង់ទៅទិញនៅឯស្រុកវិញហើយខ្ញុំមកនៅភ្នំពេញគ្រាន់ដោះទាល់ទេបំណងខ្ញុំចង់ទៅរស់នៅឯស្រុកកំណើតវិញ។

ក៖ អ្នកមីងចង់រស់នៅឯជនបទវីញមែន។

ខ៖ ចាំ!
ចង់ទៅធ្វើស្រែចំការវិញតែយើងទាល់ហើយយើងមកនៅមួយរយៈពេលសិនទៅនិង។

ក៖ ចាំ! ពេលដល់ខែច្រូតស្រូវទៅវិញទៅ។

ខ៖ អត់ទេ! តែយើងរកស៊ីជាប់តែដល់ពេលយើងបានលុយកាកគ្រប់ហើយចាំយើងទៅវិញហើយ។

ក៖ អត់ចង់រស់នៅទីក្រុងភ្នំពេញទេអ្នកមីង។

ខ៖ ទីក្រុងភ្នំពេញស្រួលរស់នៅតែយើងអត់មានដើមទុនអញ្ចឹងយើងពិបាករស់ណាស់។

ក៖ ជាចុងក្រោយអ្នកមីងមានពាក្យពេចន៍អ្វីខ្លះចង់ប្រាប់កូនចៅរបស់អ្នកមីងឲ្យគាត់ខំប្រឹងរៀន។

ខ៖ ចាំ! ចង់ឲ្យគាត់ខំប្រឹងរៀនសូត្ររកការងារល្អធ្វើកុំឲ្យពិបាកដូចខ្ញុំ។

ក៖ ចាំ! កុំឲ្យគាត់ពិបាកទៅថ្ងៃមុន។

ខ៖ ហើយឲ្យគាត់មានការតស៊ូហើយឲ្យមានការងារល្អរកលុយឲ្យបានច្រើន។

ក៖ ហើយមានពាក្យអ្វីចង់ឲ្យគាត់ជៀសវាងអ្វីដែរ។

ខ៖ ឲ្យជៀសវាងពីគ្រឿងញៀននិងល្បែងពាលាអីនិង។

ក៖ ចា! ហើយអញ្ចឹងអ្នកមីងមានតែប៉ុណ្ណឹងទេអ្នកមីង។

ខ៖ ចាំ!

ក៖ ហើយជាចុងក្រោយខ្ញុំសូមឲ្យអ្នកមីងមានសុខភាពល្អលក់ថ្ងៃនេះឲ្យដាច់ហើយពេលគាត់ចូលមកស្ដីដណ្ដឹងកូនអ្នកមីងសុទ្ធតែជាមនុស្សល្អហើយជាចុងក្រោយខ្ញុំជូនពរអ្នកមីងជួបតែមនុស្សល្អ។ខ្ញុំសូមអរគុណដែលអ្នកមីងឲ្យខ្ញុំសម្ភាសន៍ជីវប្រវត្តិរបស់អ្នកមីងសូមអរគុណ។